**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈបញ្ជាការដឹកនាំ បញ្ជាត្រួតពិនិត្យ**
**ការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក**

លេខ: ០៣៧ សណន/គបចគ

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក

កន្លងមកមន្ត្រីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកនៅរាជធានី ខេត្ត ក្រុង ស្រុក ឃុំ ទូទាំងប្រទេស បានយកចិត្តទុកដាក់ដោយស្មារតីទទួលខុសត្រូវក្នុងការគោរពប្រតិបត្តិច្បាប់ចរាចរណ៍ផ្លូវគោក រួមចំណែកធ្វើឱ្យសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកកាន់តែមានលក្ខណៈល្អប្រសើរ និងកាត់បន្ថយបាននូវគ្រោះថ្នាក់ចរាចរណ៍។

ទោះបីយ៉ាងណាក៏ដោយ គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ពិនិត្យឃើញថាបញ្ហាចរាចរណ៍ផ្លូវគោកនៅតែជាវិញ្ញាសាប្រឈមមួយយ៉ាងក្តៅគគុក អាស្រ័យដោយមូលហេតុជាច្រើនមានជាអាទិ៍៖

-ការមិនទាន់គោរពច្បាប់ចរាចរណ៍ផ្លូវគោកពីសំណាក់អ្នកប្រើប្រាស់ទ្រូងថ្នល់

-បាតុភាពនៃការធ្វើ “ អន្តរាគមន៍ ” ដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក

-មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក នៅមិនទាន់អនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានម៉ឺងម៉ាត់ នៅមានការអនុគ្រោះដោយអន្លើ ម៉្យាងទៀតសីលធម៌ អាកប្បកិរិយាធ្វើការនៅកន្លែងមួយចំនួនមិនទាន់បានសមស្របនៅឡើយ។

អាស្រ័យហេតុនេះ ដើម្បីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព ជាពិសេសអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលបានផ្តល់ជូននៅទីស្តីការក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ កន្លងមកនោះ គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក សូមធ្វើការណែនាំដល់មន្ត្រីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកដូចខាងក្រោម ៖

១-ក្រសួងមហាផ្ទៃ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបន្តហ្វឹកហ្វឺនមន្ត្រីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក អោយចេះច្បាស់លាស់អំពីច្បាប់ចរាចរណ៍ផ្លូវគោក ចេះអំពីវិធីសាស្រ្តប្រាស្រ័យទាក់ទង មានអាកប្បកិរិយាសមរម្យពេលអនុវត្តន៍ច្បាប់ជាមួយប្រជាពលរដ្ឋ ក្នុងន័យម៉ឺងម៉ាត់អនុវត្តន៍ភារកិច្ច និងការអប់រំលើកកម្ពស់ការយល់ដឹងច្បាប់ដល់ប្រជាពលរដ្ឋ ដែលអនុវត្តន៍ខុសឆ្គង។

២-មន្ត្រីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើជាគំរូល្អក្នុងការអនុវត្តន៍ច្បាប់ ដោយខិតខំលុបបំបាត់នូវអំពើអសកម្មផ្សេងៗ ។ ក្នុងករណីមានពាក្យបណ្ដឹង និងត្រួតពិនិត្យឃើញមានការខុសឆ្គងក្នុងការអនុវត្តន៍ភារកិច្ច នោះបុគ្គល ឬ អង្គភាពដែលអនុវត្តខុសឆ្គង ត្រូវទទួលវិន័យរដ្ឋបាល ឬ ទណ្ឌកម្មតាមផ្លូវច្បាប់ ។

៣-ក្នុងភារកិច្ចត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ត្រូវយកចិត្តទុកដាក់ និងម៉ឺងម៉ាត់បំផុតចំពោះអ្នកប្រើប្រាស់យានយន្តគ្មានប័ណ្ណបើកបរ អ្នកបើកបរយានយន្តមានជាតិស្រវឹង ឬ នៅក្រោមឥទ្ធិពលគ្រឿងញៀនប្រើប្រាស់យានយន្តគ្មានផ្លាកលេខ គ្មានកញ្ចក់មើលក្រោយ គ្មានពាក់ការពារមួកសុវត្ថិភាព បើកបរលឿនហួសកម្រិតមិនគោរពភ្លើងសញ្ញាចរាចរណ៍ ដឹកជញ្ជូនលើសចំណុះ ឬ សំពីងសំពោងខុសបទដ្ឋានបច្ចេកទេស និងបទល្មើសចរាចរណ៍ផ្សេងទៀត ដែលមានចែងក្នុងច្បាប់ចរាចរណ៍ផ្លូវគោក ។

៤-មន្ត្រី និងអង្គភាពអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកគ្រប់លំដាប់ថ្នាក់ ត្រូវឈរលើគោលការណ៍ច្បាប់ឯករាជ្យភាពរបស់សមត្ថកិច្ច និងយុត្តិធម៌ លុបបំបាត់បាតុភាពនៃការ **អន្តរាគមន៍** ក្នុងគោលដៅធានាកិត្តិយសសេចក្តីថ្លៃថ្នូររបស់កងកម្លាំងអនុវត្តន៍ច្បាប់ ដើម្បីឱ្យច្បាប់ត្រូវបានអនុវត្តន៍ដោយស្មើភាពគ្នា និងគ្រប់ៗគ្នានៅក្នុងសង្គម ។ ក្នុងករណីចាំបាច់ មន្ត្រីអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ត្រូវរាយការណ៍ជាបន្ទាន់តាមឋានានុក្រម ។

ទទួលបានសេចក្តីណែនាំនេះ ត្រូវចាត់ចែងផ្សព្វផ្សាយ អប់រំ ណែនាំ ដល់មន្ត្រីទាំងអស់ និងចាត់អនុវត្តន៍ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**គណៈបញ្ជាការដឹកនាំ បញ្ជា**

**ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក**

**ស ខេង**

<u>ចម្លងជូន ៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ក្រសួង និងស្ថាប័នក្នុងគណៈបញ្ជាការដឹកនាំ បញ្ជា
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ៖ លោក ឈឹម ទីណា